Reçu le 13-3-51

INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# មិត្តសាលាបាលី

ទស្សនាវដ្ដីផ្សាយពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ



ឆ្នាំទី ១ តុលា លេខ ១០

ព. ស. ២៤៩៣ – គ. ស. ១៩៥០

ទស្សនាវដ្តីអនុមាសផ្សាយព្រះពុទ្ធសាសនានិងអក្សរសាស្ត្រខ្មែរ

បណ្ណាធិការ **ឈឹម - ក្រសេម**

. សំណាក់ការ លេខ ៣៥ ភា., វិថីឧកញ៉ាពេជ្រ ក្រុងភ្នំពេញ

## បញ្ជីរឿង


| | | ទំព័រ |
|---|---|---|
| វិចារណកថា | | ៣៦១ |
| លំនាំនៃព្រះអភិធម្ម (តមក) | ភិក្ខុនារទៈ | ៣៦៣ |
| ប្រស្នានៃការកើតទៀត | សុភមិត្រ | ៣៧២ |
| ប្រវត្តិព្រះពុទ្ធវង្ស ម៉ី | | ៣៨០ |
| ក្បួនមេកាព្យ | ឧកញ៉ាសុត្តន្តប្រីជាឥន្ទ | ៣៨៤ |
| ការសាងអាយតនៈ | តែ - ង៉ុន | ៣៩០ |
| បញ្ចតន្ត្រៈ (តមក) សេចក្តីប្រែរបស់ | ភិក្ខុហ៊ាង - ខាត់ | ៣៩៥ |


---


ដំឡៃជាវ

| | |
|---|---|
| ១ ឆ្នាំ | ៩៦រ,០០ |
| ១ ឆមាស | ៤៨, ០០ |
| ១ ត្រីមាស | ២៤, ០០ |
| ១ ក្បាល | ៨, ០០ |


---

អ្នកអានទាំងឡាយ! សូមអញ្ជើញបុះឈ្មោះជាវ!

នឹងបបួលញាតិមិត្តជួយជាវ!

ជីវិតទស្សនាវដ្តីសូមផ្ញើលើលោកអ្នក ។

# វិចារណកថា

សត្វទាំងឡាយរមែងត្រូវការប្រាថ្នាសេចក្ដីសុខ ហើយស្អប់ខ្ពើមរអើមទុក្ខ នេះជាពុទ្ធភាសិត ។ យើងបានដឹងមកហើយថា ដើម្បីនឹងបានមកនូវសេចក្ដីសុខនោះ យើងគោងតាំងចិត្តជាអ្នកឲ្យ កុំពេញចិត្តក្នុងការទទួលឲ្យហួសហេតុពេក ក្នុងពេលនេះ យើងនឹងពិចារណាពីការឲ្យនេះ តើគួរឲ្យនូវអ្វីខ្លះ ។

តាមព្រះពុទ្ធសាសនា លោកប្រដៅឲ្យឲ្យរបស់ប្រាំយ៉ាងដែលទុកជាសិក្ខាបទសំខាន់នៃឧបាសក-ឧបាសិកាទាំងឡាយ គឺ :

**១ កុំសំឡាប់សត្វ** – គឺការឲ្យនូវជីវិតដល់សត្វ ដើម្បីឲ្យអស់ទោនូវសេចក្ដីរង្កៀសដល់គ្នា ដោយការផ្សាយមេត្តាទូទៅ ព្រោះការសំឡាប់សត្វនេះ នាំឲ្យសាងគ្រឿងអាវុធសំរាប់ការពារជីវិតនឹងចិញ្ចឹមជីវិតរបស់ខ្លួនដោយជីវិតអ្នកដទៃ ។

**២ កុំលួចទ្រព្យគេ** – គឺការឲ្យនូវវត្ថុប្រើប្រាស់ដល់អ្នកដទៃ ដើម្បីញ៉ាំងជីវិតឲ្យប្រព្រឹត្តបានដោយស្រួល, ការដណ្ដើមយកដីធ្លីអ្នកដទៃឲ្យគេបានសេចក្ដីលំបាកចិត្តក៏ឈ្មោះថាលួចដែរ សូម្បីបើយកមកបំពេញអត្តកម្មឲ្យបានដល់បរិបូណ៌ឡើងក៏ដោយ ។

**៣ កុំលួចប្រពន្ធកូនគេ** – គឺការឲ្យនូវសេចក្ដីសង្ឃឹមដល់អ្នកដទៃ អ្នកដែលព្យាយាមប្រកបការងារ: ដោយមិនខ្លាចនឿយព្រួយ

លំបាក ព្រោះនឹកសង្ឃឹមថានឹងបានញុាំងជីវិតប្រពន្ធកូនឲ្យបានស្រួល កាលបើមានគេមកលួចនូវប្រពន្ធកូនរបស់ខ្លួនហើយ ក៏ដូចជាសំឡាប់នូវសេចក្តីសង្ឃឹមរបស់ខ្លួន ។

៤ កុំពោលពាក្យកុហក — គឺការឲ្យនូវសេចក្តីពិតជាហេតុនាំឲ្យទុកចិត្តមូលមិត្តស្និទ្ធស្នាលដល់គ្នា ឲ្យអស់ទៅនៃសេចក្តីតូចចិត្ត ឬកាក់អន់ចិត្ត លែងកើតសត្រូវដល់គ្នា ។

៥ កុំផឹកទឹកស្រវឹង — គឺការឲ្យនូវសេចក្តីគោរពដល់អ្នកទាំងពួង; អ្នកសេពសុរា រមែងវិបត្តិបាត់បញ្ចេញនូវចរិយាអាក្រក់ដល់គេឯងជាទោសសត្រូវដល់គ្រួសាររបស់ខ្លួនទាំងអ្នកជិតខាង ។

សិក្ខាបទទាំង៥ នេះ លោកឲ្យឈ្មោះថាសីល; អ្នកបរិបូណ៌ដោយសីលបែបនេះឈ្មោះថាមានសីលធម៌ពិតប្រាកដ ។

ដូច្នេះ សីលធម៌នោះគឺការឲ្យនូវសេចក្តីសុខស្រួលដល់អ្នកដទៃ ដោយការស្ងួនកាយនិងវាចារបស់ខ្លួនឲ្យរាបសាមិនឲ្យប្រទូសប្រទាំង ប៉ះទង្គិចគ្នា ។ គួរយើងពេញចិត្តកាន់សីលធម៌បែបនេះ ហើយខំប្រតិបត្តិតាមដោយខ្នះខ្នែង ទើបពេញលេញជាអ្នកស្វែងរកសេចក្តីសុខ ។

ម្នាលអានន្ទ! អ្នកណាមួយ ទោះជាភិក្ខុ ជាភិក្ខុនី ជាឧបាសក ជាឧបាសិកា ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្ដីគោរពក្រែង ប្រព្រឹត្តតាមធម៌, អ្នកនោះទើបឈ្មោះថា ធ្វើសក្ការៈ គោរព រាប់អាន និងបូជា ចំពោះតថាគត ដោយការបូជាដ៏ប្រសើរបំផុត ។

មហាបរិនិព្វានសូត្រ មហា. វ័យ.

## លំដាប់នៃព្រះអភិធម្ម

(តមក)

តាមព្រះអភិធម្ម យើងរស់នៅបានក្នុង ១ ខណៈចិត្ត ប្រព្រឹត្តទៅក្នុងបច្ចុប្បន្នកាលជានិច្ច ។

ក្នុង១ខណៈចិត្តមាន ៣ ថ្នាក់ គឺឧប្បាទ ឋិតិនិងភង្គ ខណៈចិត្តមួយរលត់ទៅដើម្បីឲ្យកើតខណៈចិត្តថ្មីមួយឡើង, ខណៈចិត្តដែលកើតជាលំដាប់មក មិនមែនដែលដូចខណៈចិត្តដើមដែលជាប់ៗគ្នានោះទេ ព្រោះមានគ្រឿងផ្សំមិនដូចគ្នា ប៉ុន្តែមិនមែនដាច់ផ្សេងពីគ្នាសុទ្ធសាធនោះទេ ពីព្រោះជាក្រសែនៃកំឡាំងកម្មតែមួយ ។

តែកុំច្រឡំថាចិត្តត្រូវកាត់ដាច់ជាដុំៗ តភ្ជាប់គ្នាដូចជាខ្សែអយស្ម័យ-យានឬខ្សែច្រវាក់នោះឲ្យសោះ, មិនដូច្នោះទេ "ចិត្តនេះហូរទៅដូចស្ទឹង

ដែលទទួលនូវក្រសែទឹក គឺអារម្មណ៍ចាក់ចូលមកក្នុងក្រសែរបស់ស្ទឹងនោះជានិច្ច ហើយផ្សាយចេញទៅក្នុងលោកខាងក្រៅនូវក្រសែចិត្តដែលបានទទួលតាមផ្លូវមក" មានការកើតជាប្រភព មានការស្លាប់ជាមាត់ពាម ។

ត្រង់នេះយើងឃើញថាការបន្តគ្នានៃខណៈចិត្តមួយដំណើរៗ ផ្ទុយគ្នានឹងការតំរួតគ្នាលើគ្នានៃខណៈចិត្ត ។ ឥតមានខណៈចិត្តណាមួយ ដែលកន្លងហួសទៅហើយនឹងវិលត្រឡប់មកវិញដដែលៗ សុទ្ធៗ ដូចខណៈចិត្តដែលកន្លងផុតទៅហើយនោះទេ, ចិត្តតែងប្រែប្រួលជានិច្ចឥតមានដូចគ្នាក្នុងពីរខណៈចិត្តទេ ។

ខណៈចិត្តនីមួយៗតែងប្រកបដោយចេតសិកមិនឋិតថេរ ។ ចេតសិកមាន ៥២ ។

តាមសេចក្ដីពោលនេះ ពុំមានចិត្តដោយឡែកផ្សេងពីគុណរបស់ចិត្តទេ វេទនាមានទូទៅគ្រប់ចិត្ត; វេទនាមាន ៥ ប្រភេទគឺសុខ ទុក្ខ សោមនស្ស ទោមនស្ស ឧបេក្ខា ។

សុខនឹងទុក្ខសុទ្ធជាវេទនាខាងកាយ ក្រៅពីនោះសុទ្ធតែខាងចិត្ត ។ វិញ្ញាណទូទៅ គឺក្នុងមួយជីវិត មានពិសោធតែចិត្ត ២ ដួងដែលប្រកបដោយទោមនស្ស ហើយនឹងចិត្តតែ ១ ដួងដែលប្រកបដោយទុក្ខតែប៉ុណ្ណោះ ឯចិត្តដទៃជាសោមនស្សឬជាឧបេក្ខា, ខនេះជាការសំខាន់មួយដែលអ្នករិះគន់ព្រះពុទ្ធសាសនាថាជាសាសនានៃសេចក្ដីទុក្ខគប្បីពិចារណាឲ្យហ្មត់ចត់ ។

ចេតនាជាសម្បត្តិសំខាន់មួយរបស់ចិត្តសាកល (សាធារណៈ) ចិត្តនីមួយៗ ចាត់ជាចេតនា, ដោយហេតុនោះ យើងត្រូវទទួលខុសត្រូវចំពោះគ្រប់ចិន្តារបស់យើង ។ ក្នុងការទាក់ទងគ្នានោះ គេងកំណត់ញែកចេតនានឹងបំណងឲ្យស្រឡះចេញពីគ្នា គួយ៉ាងដូចយើងកំពុងដើរ យើងអាចជាន់សត្វល្អិត ដោយប្រាសចាកបំណងនឹងសំឡាប់, នេះជាអំពើធ្វើដោយមិនដឹងខ្លួន មានចេតនានឹងដើរមែន តែគ្មានបំណងនឹងសំឡាប់ទេ ។

មានសម្បត្តិរបស់ចិត្តសាកល ១ ទៀត ឈ្មោះជាសញ្ញាតិសការ ចិត្តដែលបើកឲ្យយើងនឹករលឹកអំពើបុគ្គលិកដែលកន្លងហួសទៅ ហើយនោះបាន, សតិនឹងកើតឡើងបានដោយអាស្រ័យសម្បត្តិរបស់ចិត្តនេះឯង ។

តាមព្រះពុទ្ធសាសនា ជីវិតរបស់កាយមានយ៉ាងណា ជីវិតរបស់ចិត្តក៏មានយ៉ាងនោះដែរ, ជីវិតនេះឈ្មោះថាជីវិតិន្ទ្រិយ៍, នាមមិនអាចតាំងនៅបានដោយខ្វះសម្បត្តិនេះទេ ។

នៅមានសម្បត្តិរបស់ចិត្តសាកល ៣ យ៉ាងទៀត គឺផស្សៈ ឯកគ្គតា នឹងមនសិការៈ ។

សម្បត្តិរបស់ចិត្ត ៦ ប្រការជាបកិណ្ណកៈ សម្បត្តិនេះអាចមានបុម៉ន មានក្នុងប្រភេទចិត្ត ១ ដួង ។ សម្បត្តិរបស់ចិត្ត ១៤ ជាអកុសលមាននៅក្នុងអកុសលចិត្ត ១២ ។

ខសំខាន់ក្នុងចិត្តជាអកុសល គឺចិត្តនោះតែងប្រកបដោយសម្បត្តិ ៤ យ៉ាង គឺ មោហៈ អហិរិកៈ អនោត្តប្បៈ និងឧទ្ធច្ចៈជានិច្ចដោយហេតុនោះ អ្នកការពុទ្ធសាសនាពោលថា មោហៈជាឫសគល់នៃអំពើបាប ។

ដោយខ្មើមអំពើបាប និងដោយខ្លាចផលដែលអំពើបាបហុចមកឲ្យ នោះឯង បានជាគេវៀរចាកមិនប្រព្រឹត្តអំពើបាប ។ អ្នកគ្មានគុណធម៌ទាំងពីរ ២ ប្រការក្នុងខ្លួន អាចនឹងធ្វើបាបបានដោយឥតរង្វង់ ទើបព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា ហិរិនិងឱត្តប្បៈនេះជាធម៌រក្សាលោក ២ ប្រការ (លោកបាលធម៌) ។

ពេលដែលគេធ្វើបាប ចិត្តក៏សៅហ្មងព្រោះដឹងជាក់ជាខ្លួនធ្វើនូវអំពើបាប, ដូច្នេះឧទ្ធច្ចៈនៅក្នុងអកុសលចិត្តគ្រប់ប្រភេទ ។

ចេតសិក ១៩ មានទូទៅគ្រប់សាកលចិត្ត និង ៦ ទៀតមិនសាធារណ៍ក្នុងគ្រប់ៗ ចិត្តទេ ។

កាលបានស្គាល់ច្បាស់ នូវសម្បត្តិផ្សេងៗរបស់ចិត្តហើយ គេអាចកត់សំគាល់បាន ដោយច្បាស់លាស់នូវចេតសិក ដែលមានប្រាកដនៅក្នុងប្រភេទចិត្តនីមួយៗ ។

ចិត្តដែលប្រកបដោយចេតសិកប្រែប្រួល តែងទទួលនូវអារម្មណ៍មកពីខាងក្រៅ ។ បើជនម្នាក់ដេកលក់ស៊ប់ ចិត្តអ្នកនោះនៅក្នុងសភាពទំនេរ គឺជាក្នុងសភាពជាភវង្គ ។ យើងពិសោធនូវសភាវចិត្តបែបនេះ

ក្នុងពេលដែលចិត្តរបស់យើងមិនរវះរវាមតបនឹងអារម្មណ៍ខាងក្រៅ ៗ សភាពចិត្តនេះ ឬភវង្គនឹងដាច់ទៅដោយមានអារម្មណ៍មកប៉ះនឹងចិត្ត ភវង្គ-ចិត្ត ដែលគេពិសោធជានិច្ចកាលនោះ បើគ្មានអ្វីចូលមកកាត់ផ្តាច់ទេ ក៏រមែងកំរើកញ័រអស់ ២ ខណៈចិត្ត ហើយទើបរលត់ទៅវិញ, ក្នុងលំដាប់នោះបញ្ចទ្វារាវជ្ជនៈកើតឡើងហើយរលត់ទៅ ឯក្រែសធម្មតាក៏ដាច់ទៅ ហើយឡើងកាន់អារម្មណ៍ ៗ ក្នុងមួយរំពេចនោះ ចក្ខុវិញ្ញាណកើតឡើង ហើយរលត់ទៅជាលំដាប់ សម្បដិច្ឆនៈទទួលយកនូវអារម្មណ៍ សន្តីរណៈចាប់ពិចារណានូវអារម្មណ៍មួយសន្ទុះ ទើបដល់ថ្នាក់នៃការកំណត់នូវអារម្មណ៍ ហៅថាវោដ្ឋវនៈ ដ៏ជាកិច្ចសំខាន់ សំរាប់ឲ្យកើតកិច្ចជាលំដាប់តទៅ គឺជវនការសេពសោយនូវអារម្មណ៍, តាមធម្មតាជវនមានកំណត់ ៧ ខណៈចិត្ត ឬ ៥ ខណៈចិត្តក្នុងពេលស្លាប់ ៗ វិថីចិត្តទាំងមូលដែលប្រព្រឹត្តទៅក្នុងចំណែកពេលជាអតិសុខុមកាល អស់ត្រឹមតទាលម្ពណៈចិត្តដែលស្រាវយក ឬ គោងយកនូវអារម្មណ៍ក្នុងការៈ ២ ខណៈចិត្ត ៗ ដូច្នេះ វិថីចិត្តតាំងទៅគ្រប់បរិបូណ៌ អស់កំណត់កាល ១៧ ខណៈចិត្ត ដល់ខណៈជាសំខាន់នៃជវនទើបកើតកម្មល្អ និងអាក្រក់ឡើង ៗ

វិថីចិត្តប្រព្រឹត្តតៗ គ្នាដូច្នេះ ១ – អតីតភវង្គ ; ២ – ភវង្គចលនៈ ៣ – ភវង្គុបច្ឆេទ; ៤ – អាវជ្ជនៈ; ៥ – វិញ្ញាណ; ៦ – សម្បដិច្ឆនៈ; ៧ – សន្តីរណៈ; ៨ – វោដ្ឋវនៈ; ៩ - ១០ - ១១ - ១២ - ១៣ - ១៤ - និង ១៥ – ជវន; ១៦ – និង ១៧ – តទាលម្ពណៈ ៗ

អារម្មណ៍ដើមស្វាយ អាចទាញយកមកប្រៀបធៀបបំភ្លឺដំណើរវិថីចិត្ត ដែលសម្ដែងខាងលើនេះ ។ បុរសម្នាក់ទទូរក្បាលដេកលក់ស៊ប់ក្រោមដើមស្វាយមួយដើម លុះខ្យល់បក់ប៉ះមែកស្វាយ, ផ្លែស្វាយមួយក៏ជ្រុះមកជិតបុរសដេកលក់នោះ បុរសនោះក៏ភ្ញាក់ចាកដំណេកគ្មានយល់សប្តិ បើកសំពត់គ្របក្បាលចេញដើម្បីមើលអ្វីដែលធ្វើឲ្យខ្លួនភ្ញាក់ ឃើញផ្លែដែលទើបនឹងជ្រុះ ក៏រើសឡើងយកមកពិនិត្យមើល ឃើញជាផ្លែប្រកបដោយគ្រឿងផ្សំ នឹងគុណសម្បត្តិ ដែលខ្លួនធ្លាប់បានសង្កេត ក្នុងពេលដែលបានពិចារណាពីពេលមុនមក ស្គាល់ច្បាស់ជាផ្លែស្វាយ ហើយបរិភោគនូវផ្លែស្វាយនោះ រួចទទូរក្បាលប្រែះដេកទៅវិញ ។

ដំណេកគ្មានយល់សប្តិ ប្រៀបដូចក្រសែភវង្គដែលគ្មានអ្វីមកប៉ះពាល់, ខ្យល់យោកដើមស្វាយ ដូចខណៈជីវិត ក្នុងពេលដែលអារម្មណ៍ចូលក្នុងក្រសែហើយច្របល់ក្នុងលេក ដោយឥតធ្វើឲ្យសៅហ្មង, មែកដែលកំរើកដោយកំឡាំងខ្យល់ជាភវង្គចលនៈ, ផ្លែឈើដែលជ្រុះមកដូចការឈប់ឬការដាច់ទៅនៃភវង្គ បានដល់ខណៈដែលចូលមកកាត់ក្រសែ, ការក្រោកឡើងនៃអ្នកដេក បានដល់ការនឹកពារកអារម្មណ៍ដោយទ្វារ, ការបើកមុខចេញពីការទទូរ គឺបដិកិរិយានៃចក្ខុបសាទ, កិរិយារើសនូវផ្លែស្វាយដូចការទទួលយកនូវអារម្មណ៍, ការស្គាល់នូវផ្លែដោយគ្រឿងផ្សំនឹងគុណពិសេសខ្លះៗ នោះ បានដល់កិច្ចកំណត់ឬសំគាល់នូវអារម្មណ៍

ការបរិភោគនូវផ្លែស្វាយ  បានដល់ជវនកិច្ចការសេពសោយនូវអារម្មណ៍ក្នុងទីបំផុត,  កិច្ចលេបបង្ហើយនូវសាច់ស្វាយដុំក្រោយបង្អស់នៅក្នុងមាត់បានដល់តទាលម្ពណៈកិច្ច  កិច្ចស្រាវចុះកាន់ភវង្គ  ដូចបុរសដែលប្រែះដេកទៅវិញ ។

បើអារម្មណ៍ខាងក្រៅណាមួយ ដូចរូប សំឡេង ក្លិន រស ផោដ្ឋព្វចូលក្នុងក្រសែចិត្ត, វិថីចិត្តប្រព្រឹត្តទៅដូចបានពោលខាងលើនេះ, បើជាធម្មារម្មណ៍ប្រាកដដល់ចិត្តវិញ វិថីចិត្តប្រព្រឹត្តទៅដូច្នេះ ១ – អតីតភវង្គ; ២ – ភវង្គចលន; ៣ – ភវង្គុបច្ឆេទ; ៤ – មនោទ្វារាវជ្ជនៈ; ៥-៦-៧-៨-៩-១០-ទឹង ១១-ជវន; ១២ ទឹង ១៣-តទាលម្ពណៈ ។

គប្បីកំណត់ទុកថាវិថីចិត្តធម្មតា  ប្រកបដោយរូបជាអារម្មណ៍មាន ១៧ ខណៈចិត្ត  រាប់ជាអាយុរូបធម៌ ១ ។

រូបារម្មណ៍ដែលតាមធម្មតាប្រព្រឹត្តទៅគ្រប់ ១៧ ខណៈចិត្តឈ្មោះថាអតិមហន្ត (ដ៏ធំក្រៃលែង); ក្នុងករណីនេះ  ការផ្ចិតនូវអារម្មណ៍ខ្លាំងក្លាណាស់ ។  អារម្មណ៍ដែលតាំងនៅក្នុងវិថីចិត្តបានត្រឹមតែជវនការៈមិនទាន់ដល់តទាលម្ពណៈនៅឡើយឈ្មោះថាមហន្ត (ធំ) ។ អារម្មណ៍ដែលមានសន្ទុះខ្សោយមិនក្លៀវក្លា  មិនអាចតាំងនៅបានរហូតដល់ជវនវិថីក្នុងខនេះ  វិថីចិត្តហូរដល់វោដ្ឋព្វនការៈក៏ធ្លាក់ចុះកាន់ខ្សែភវង្គ  ឈ្មោះថា

បរិត្ត ៗ អារម្មណ៍ដ៏ទន់ខ្សោយ (អតិបរិត្ត) ចូលដល់បញ្ចទ្វារឲ្យកើតត្រឹមភវង្គចលនប៉ុណ្ណោះ (មោឃវារៈ) ៗ

ដូច្នេះអារម្មណ៍ដែលប្រព្រឹត្តទៅក្នុងបញ្ចទ្វារមាន ៤ ប្រការគឺ

១) អារម្មណ៍ដែលអស់ត្រឹមតទាលម្ពណវារៈ

២) អារម្មណ៍ដែលអស់ត្រឹមជវនវារៈ

៣) អារម្មណ៍ដែលអស់ត្រឹមវោដ្ឋព្វនវារៈ

៤) អារម្មណ៍ដែលអស់ត្រឹមភវង្គចលនវារៈស្ទួចស្តើងបំផុត (មោឃវារៈ)

ខាងធម្មារម្មណ៍វិញ បើវិថីចិត្តតាំងនៅដល់តទាលម្ពណៈ អារម្មណ៍នោះឈ្មោះថាវិភូត (ច្បាស់) ៗ បើអស់ត្រឹមជវនតទាលម្ពណមិនអាចកើតឡើងបាន អារម្មណ៍នោះឈ្មោះថា អវិភូត (មិនច្បាស់) ៗ

ភវង្គចិត្តដែលវិលទៅតាមអំណាចកំឡាំងកម្ម តែងហូរមិនដាច់ អារម្មណ៍ដែលដិតទុកចាកបសាទ ជាសាខាធ្លាក់ខ្ទប់ក្នុងចិត្តត្រលប់ ៗ

ដែលយើងហៅថាស្លាប់នោះ គ្រាន់តែជាការអស់ទៅមួយខណៈនៃធាតុផងការណ៍ (ធាតុភូត) មួយខណៈ (សង្ខារធម៌) ប៉ុណ្ណោះ ៗ ពិតមែនជាកងកាយបែកធ្លាយទៅតាម ឥន្ទ្រិយ៍ ជីវិតនឹងចិត្ត តែក្រសែចិត្តនៅមិនទាន់សាបសូន្យនៅឡើយទេ ព្រោះកម្មវិបាកសេសសល់នៅឡើយ ៗ

តាមព្រះពុទ្ធសាសនា ស្លាប់ដោយហេតុ ៤ យ៉ាង គឺ:

១) ដោយអស់អាយុ (អាយុក្ខ័យ)

២) ដោយអស់កម្ម (កម្មក្ខ័យ)

៣) ដោយអស់អាយុនិងកម្មព្រមគ្នា (ឧភយក្ខ័យ)

៤) ដោយកម្មចូលទៅកាត់បង់ (អកាលមរណៈ)

កាលណាកាយទ្រុឌទ្រោមទៅ វិបាកតែងជាតិថ្មី ជាសត្វកើតក្នុងពង (អណ្ឌជ), កើតក្នុងគភ៌ (ជលាពុជ), កើតដោយញើសក្អែល (សំសេទជ) ឬកើតឡើងឯង (ឧបបាតិក) ។ គោងចាំជាកំណើតខាងក្រោយនេះ ក៏មានកម្មជាបច្ច័យដែរ ។

## រូប

រូបជាបរមត្ថធម៌ទី ៣ ។ "រូប" ប្រែថា អ្វីដែលប្រែប្រួលឬដែលទ្រុឌទ្រោម (រុប្បតិ តិដ្ឋតីតិ រូបំ) ។

ក្នុងគម្ពីររូបនេះ ព្រះអភិធម្មសង្គហ មិនបញ្ចូលត្រឹមតែ រូបធាតុប៉ុណ្ណោះទេ គឺរួមទាំងគុណសម្បត្តិនៃរូបធាតុផង :

គុណសម្បត្តិនៃរូបធាតុមាន ២ ជាន់ គឺមហាភូតរូប និងឧបាទាយរូប ។

១) មហាភូតរូបនោះ គឺ បឋវី អាបោ តេជោ និងវាយោ ;

២) បសាទរូបនោះ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ;

៣) គោចររូបនោះ គឺ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍និង ផោដ្ឋព្វារម្មណ៍ តែផោដ្ឋព្វារម្មណ៍គ្មានអាបោធាតុទេ ។ (មានត)

# ប្រស្នានៃការកើតទៀត

តាំងពីអតីតកាលរៀងមកមនុស្សសត្វទាំងឡាយមិនពេញចិត្តនឹងសេចក្ដីស្លាប់ទេ តែងស្វះស្វែងរកអមតធម៌ឥតស្រាក ទើបអមតធម៌នេះមានពោលក្នុងសាសនាខ្លះទៅ ។ មេសាសនាពន្យល់អ្នកកាន់តាមឲ្យព្យាយាមគោរពយកនូវអមតធម៌នោះ ដោយប្រតិបត្តិតាមពាក្យប្រៀនប្រដៅក្នុងសាសនាខ្លួននោះ ។ ដើម្បីមិនបង់ឲ្យមានការស្លាប់ស្អាត់ពីមុខ ពុំមែនដើម្បីឲ្យសោយទុក្ខវេទនាជានិច្ចនោះទេ គឺឲ្យបានទទួលនូវសេចក្ដីសុខពេញបរិបូណ៌បិតថេរ ។ អ្នកធ្វើឃាតដល់ខ្លួនឯង ព្រោះផុតផ្លូវសង្ឃឹមក្នុងជាតិនេះ គង់មានសង្ឃឹមថានឹងបានសុខជាងពេលនេះក្នុងជាតិខាងមុខដែរ ។ សេចក្ដីប្រាថ្នាដែលដុះជាប់ក្នុងចិត្តនៃមនុស្សសត្វទាំងឡាយដ៏ជ្រាលជ្រៅបែបនេះ គង់តែមានពេលនឹងអាចសំរេចបាន តែលោកនេះឥតមាននរណាបានទទួលសេចក្ដីសុខដ៏បរិបូណ៌ឡើយ ហើយត្រូវស្លាប់គ្រប់ៗរូប ដូច្នេះត្រូវតែស្លាប់ហើយកើតទៀត រហូតដល់បានសំរេចនូវសេចក្ដីប្រាថ្នាដើមនោះ ។

កាលយើងបោលភ្នែកក្រឡេកមើលជុំវិញខ្លួនយើងទៅ យើងសង្កេតឃើញថា មនុស្សក្នុងលោកនេះតែងខុសៗគ្នាពីរូបមួយទៅរូបមួយ ទាំងរូបសម្បត្តិ ទាំងលក្ខណសម្បត្តិ ដោយហេតុអ្វីបានជាដូច្នេះ? នឹងថាព្រោះពូជក៏ពុំមែន ព្រោះឧបត្តិហេតុ ឬព្រោះអំណាចស័ក្ដិសិទ្ធិ

ឯណាបង្កើតក៏ពុំមែនដែរ បើជាដូច្នោះពិតមែន គោងតែកើតមកហើយ មានសភាពដូច ៗ គ្នា ឬ ក៏ស្រដៀង ៗ គ្នា មិនខុសដល់ទៅមួយជាអ្នកបរិបូណ៌ដោយរូបសម្បត្តិ មួយទៀតមានអវយវៈវិកលវិការ ឬមួយជាអ្នកស្លូតត្រង់ មួយជាចោរដូច្នេះទេ មួយសោតទឹងថាព្រោះការសេពគប់ឬ? ក៏ឃើញថាខុសគ្នាពីកំណើតមកផង ៗ ព្រះពុទ្ធសាសនាបានប្រាប់ដោយច្បាស់លាស់ថា: "សព្វសត្វទាំងអស់ មានកម្មជារបស់ខ្លួន កម្មជាមរតក កម្មជាកំណើត កម្មជាផៅពង្ស កម្មជាទីពឹង កម្មនេះឯងធ្វើសត្វឲ្យខុស ៗ គ្នាក្នុងទីខ្ពស់ទឹងទីទាប", តែពុំបានបដិសេធហេតុដទៃចោលដែរ ៗ ក្នុងព្រះអភិធម្មមានចែកនូវនិយាមប្រាំយ៉ាង គឺឧតុនិយាម ១ ពីជនិយាម ១ កម្មនិយាម ១ ធម្មនិយាម ១ ចិត្តនិយាម ១ សូម្បីបើដូច្នោះ កម្មនេះជាកត្តាដ៏សំខាន់ក្នុងកំណើតរបស់មនុស្ស ៗ កាលកំណើតក្នុងជាតិនេះ ជាបាតុភាពរបស់កម្មដូច្នោះហើយ កម្មនេះពុំអាចជាកម្មបច្ចុប្បន្នក្នុងពេលដែលចាប់កំណើតបានទេ គោងតែជាកម្មនៃអតីត គឺកម្មដែលបានធ្វើហើយក្នុងជាតិមុន ឯកម្មបច្ចុប្បន្នទឹងនាំឲ្យមានជាតិថ្មីតទៅទៀត ដូច្នេះស្លាប់ហើយ មិនសូន្យទេ ត្រូវយកកំណើតតទៅទៀត ៗ

ភិក្ខុនារទៈបានប្រកាសក្នុងរឿងកម្មថា "កម្មជាច្បាប់នៃហេតុក៏ទខាងសីលធម៌ ឯកំណើតថ្មីជាផលដ៏ត្រង់របស់កម្ម កម្មនិងកំណើតថ្មីជាធម៌ជាប់ទាក់ទងគ្នាទៅវិញទៅមក ហើយជាគោលធម៌ដ៏សំខាន់នៃព្រះ

ពុទ្ធសាសនា" ។ ដោយការស្រ័យកម្មនេះ អមតធម៌អាចនឹងជួបប្រទះបាន ដោយការសន្សំសេចក្តីល្អកាន់តែវិសេសឡើងក្នុងជាតិជាលំដាប់តទៅ ។

ពេលដែលកំពុងរស់នៅ យើងមិនចង់ឲ្យបសាទវិកលវិការដោយប្រការឯណានីមួយឡើយ ព្រោះបសាទទាំងនេះជាគ្រឿងស្រូបគ្រឿងផ្តិតយកនូវអារម្មណ៍ដែលយើងត្រូវការចង់ក្រេបរសជាតិ ដើម្បីសោយនូវទុក្ខឬសុខ តាមលក្ខណៈនឹងប្រភេទនៃអារម្មណ៍នោះ ចិត្តនឹងអាចសោយនូវទុក្ខឬសុខនោះបាន លុះតែមានអារម្មណ៍មកប៉ះនឹងបសាទខាងក្រៅឯណាមួយ ញាប់ញ័រខ្លួរខ្លាឡើងហើយបញ្ជូននូវសេចក្តីដឹងដល់ចិត្ត ។ ឧបមាថាបើយើងងងឹតភ្នែកមើលអ្វីពុំយល់ រូបារម្មណ៍ក៏មិនប្រាកដដល់ចក្ខុបសាទ ឯចក្ខុវិញ្ញាណក៏ពុំមាន ចិត្តមិនអាចនឹងសោយនូវរូបារម្មណ៍បាន នឹងអន្ទះសាស្រេកឃ្លានព្រោះខ្វះខាតនូវអាហារប្រភេទនោះ ចំដូចអ្នកចង់អាហារដែលខ្លួនបរិភោគពុំកើតព្រោះឈឺមាត់នោះឯង ។ មនុស្សងងឹតភ្នែកគង់អាចសោយនូវអារម្មណ៍ ដែលធ្លាប់បានជួបប្រទះក្នុងពេលនៅភ្លឺភ្នែកនៅឡើយ តែរូបារម្មណ៍ថ្មីលែងប្រាកដដល់ចិត្តទៀតឡើយ ។ ដោយហេតុនោះ ទើបយើងជាប់ជំពាក់យ៉ាងក្រៃលែងនឹងរាងកាយដែលទុកជាឧបករណ៍សំរាប់ផ្សំនូវគ្រឿងសប្បាយភ្លើតភ្លើនគ្រប់យ៉ាងដល់ចិត្ត ។

អារម្មណ៍ចាស់អាចឲ្យកើតអារម្មណ៍ថ្មី ឯអារម្មណ៍ថ្មីឲ្យកើតអារម្មណ៍ក្នុងកាលខាងមុខ កាលយើងឃើញសុរា យើងចង់ផឹក ព្រោះយើងធ្លាប់ស្គាល់រសជាតិពីពេលមុនមក ការស្គាល់រសជាតិសុរាក្នុងពេលនេះនាំឲ្យយើងចង់ផឹកសុរាក្នុងពេលមុខទៀត យើងរស់នៅក្នុងពេលនេះដោយអាស្រ័យអតីត ហើយសង្ឃឹមក្នុងអនាគត ដូច្នេះអតីត បច្ចុប្បន្ននឹងអនាគតពុំទីទៃផ្សេងៗពីគ្នាទេ គឺជិតជិតជាប់ទាក់ទងគ្នាយ៉ាងស្អិត ៗ ភិក្ខុអានន្ទ: បានសម្តែងថា "ប្រស្នាដែលកើតមានឡើងនោះ គឺដោយហេតុអ្វីបានជាយើងអាចជឿដល់អតីតបាន បើយើងជឿក្នុងបច្ចុប្បន្នភ្លាមៗនេះ ក៏សមហេតុសមផលនឹងឲ្យយើងជឿក្នុងអនាគតនឹងអតីត ព្រោះបច្ចុប្បន្នពុំមែនអ្វីក្រៅពីកូននៃពីអតីតនឹងឪពុកនៃអនាគតនោះឡើយ" បានសេចក្តីថាបច្ចុប្បន្នកើតចេញពីអតីតហើយនឹងបង្កើតនូវអនាគតតទៅទៀត ៗ

ព្រោះហេតុនោះ ពេលយើងទៀបស្លាប់ យើងចង់កើតទៀត ដើម្បីក្រេបនូវរសជាតិឥដ្ឋារម្មណ៍ដែលយើងពេញចិត្ត ដែលយើងមិនទាន់សោយឲ្យបានឆ្អែតស្កប់ស្កល់នៅឡើយ ដោយអនិដ្ឋារម្មណ៍ចេះតែចូលមកបៀតបៀនជ្រៀតជ្រែកជានិច្ច នាំឲ្យតែយើងអាលោះអាល័យសោកស្តាយមិនចង់ឃ្លាតឆ្ងាយពីកាយនេះសោះ ដល់ពេលចោលរាងកាយនេះ ក៏ចង់បានរាងកាយថ្មី ដើម្បីក្រេបរសជាតិអារម្មណ៍ដែលត្រូវការ ដែលស្រណោះស្រណោកនោះតទៅ ក៏មានចិត្តជាប់ជំពាក់នឹងរាងកាយ ចក់យក

ភព ចាប់ជាតិជាថ្មី សមដូចព្រះពុទ្ធជាម្ចាស់មានតំរាស់ទៅកាន់លិច្ឆវី-មហាលីថា

“ព្រោះតែនាមនិងរូប នាំមកនូវសេចក្ដីសុខផងមិនសុទ្ធតែទុក្ខប៉ុណ្ណោះ ទើបសត្វទាំងឡាយប្រាថ្នានូវនាមរូបនោះ, ព្រោះតែសេចក្ដីប្រាថ្នានោះឯង បានជាជាប់ជំពាក់នឹងនាមរូប ព្រោះការជាប់ជំពាក់នេះ ទើបសត្វបានសេចក្ដីសៅហ្មងដោយកិលេស ។

ចំណែកព្រះអង្គ “តថាគតបានបោះបោលនូវសំលៀកបំពាក់ គឺនាមរូបចោលហើយ ពុំមានភពថ្មីដល់តថាគតទៀតឡើយ” ។ ដូច្នេះការជាប់ជំពាក់នឹងនាមរូបនាំឲ្យមានភពថ្មី គឺ ឲ្យកើតទៀត ។

ហេតុផលខាងលើនេះ យើងអាចយកមកអធិប្បាយក្នុងជាតិនេះក៏បាន យើងបានឃើញមកហើយថា អារម្មណ៍ចាស់ឲ្យកើនអារម្មណ៍ថ្មី ឬឲ្យត្រូវការអារម្មណ៍ថ្មីទៀត ក្នុងជាតិនេះ ពេលកើតមកភ្លាម យើងត្រូវការចង់បាននេះបាននោះទៅហើយ បានជាចង់បានដូច្នេះ ព្រោះធ្លាប់បានជួបប្រទះបានឃើញបានយល់បានស្គាល់រួចមកហើយ ឧបមាដូចយើងចង់ទូរេន បានជាចង់ព្រោះធ្លាប់ស្គាល់រសជាតិទូរេនមកហើយ ឬដឹងថាទូរេនមានរសជាតិឆ្ងាញ់ពិសា បើមិនធ្លាប់ភ្លក់ មិនដែលដឹង មិនដែលស្គាល់សោះ តើយើងនឹងចង់បានទូរេននោះដូចម្ដេចកើត ពេលដែលចាប់ជាតិក្នុងកំណើតថ្មី ក្នុងកាយថ្មី ដើម្បីស្វែងអារម្មណ៍នោះ ក៏

ព្រោះតែបានស្គាល់អារម្មណ៍នោះហើយ មានចិត្តជាប់ជំពាក់នឹងអារម្មណ៍នោះ គឺថាមានជាតិមុនមកហើយ កាលជាតិមុនមានហើយឲ្យកើតជាតិនេះ ជាតិនេះក៏នឹងឲ្យកើតជាតិថ្មីទៅទៀត ។

រឿងនេះលោក សឹក-គ្រីម អ្នកប្រាជ្ញពុទ្ធសាសនាជាតិអល្លឺម៉ង់ ក៏បានអធិប្បាយថា :

“បើមុននឹងចាប់បដិសន្ធិ យើងមានសេចក្ដីប្រាថ្នាមានឆន្ទចង់មានរាងកាយ បើយើងជាប់ជំពាក់នឹងពូជដែលមាតាបិតាយើងបានចាត់ចែងហើយ (ពូជដែលជារូបរាងកាយរបស់យើង) គឺព្រោះតែសេចក្ដីប្រាថ្នាឆន្ទៈនឹងមានរាងកាយនេះ ជាសេចក្ដីប្រាថ្នាជាឆន្ទៈ នឹងទទួលនឹងសេពនូវឧប្បាទធម៌ក្នុងលោក ដោយអាស្រ័យរាងកាយនោះឯង; ដូច្នេះ ដែលយើងប្រាថ្នាបំផុតនោះ គឺក្រេបនូវរសជាតិនៃឧប្បាទធម៌នោះ យើងចង់ប៉ះសម្ផស្សឧប្បាទធម៌នោះដោយសាររាងកាយដែលជាគ្រឿងយន្តប្រកបដោយបសាទ ៦ ។ មុននឹងបានរាងកាយថ្មីនេះជាកេតនភ័ណ្ឌ ខ្ញុំមិនអាចនឹងចង់បានប្រាថ្នានូវឧប្បាទធម៌ក្នុងលោកបាន បើខ្ញុំមិនដែលធ្លាប់បានទទួលបានសេពឬបានក្រេបរសជាតិពីមុនមកសោះ ។ របស់ណាដែលខ្ញុំមិនដែលស្គាល់ ខ្ញុំក៏មិនអើពើរវល់នឹងរបស់នោះដែរ បើពោលដោយវោហារផ្សេងទៅថា អ្វីដែលខ្ញុំមិនស្គាល់ ខ្ញុំមិនត្រូវការចង់បានអ្វីទេ” ។

ដូច្នេះយើងឃើញថាជាតិនេះ កើតមានឡើងព្រោះមានជាតិមុន ឯជាតិនេះនឹងឲ្យកើតនូវជាតិជាលំដាប់តទៅទៀត មរណៈយោងមុខបដិ-សន្ធិ បដិសន្ធិយោងមុខមរណៈ ឯពាក្យបដិសន្ធិនោះឯងក៏បានសេចក្ដីថា បន្តទៅទៀត គឺបន្តជាតិឬភពនោះឯង ។

តែថាការកើតឬស្លាប់ ដែលនិយាយខាងលើនេះ គ្រាន់តែជាបញ្ញត្តិធម៌សន្មតថាកើតថាស្លាប់ប៉ុណ្ណោះ ពុំបានពោលដោយសេចក្ដីពិតនៃស-ភាពធម៌ទេ ព្រោះតាមបរមត្ថឬតាមសភាពសេចក្ដីពិត វោហារថាមនុស្ស បុគ្គលនិងសត្វជាដើម គ្រាន់តែជាពាក្យសន្មតកំណត់ឲ្យចូលចិត្តងាយប៉ុណ្ណោះ តាមពិតមានតែ រូប នាម ខន្ធ អាយតននិងធាតុ ។ ធម្មតា ខន្ធ ធាតុ ជាសំខតធម៌រមែងបរិបូណ៌ដោយលក្ខណៈទាំង ៣ គឺឧប្បាទៈ ការប្រាកដឡើង ឋិតិ=ការតាំងនៅ និងភង្គ=ការអស់ទៅគ្រប់កាល ។

ការកើតទៀតមកពីចិត្តជាប់ជំពាក់នឹងកាយ ឬ អារម្មណ៍ ៗ ដែលគេសន្មតថាសត្វ ថាបុគ្គល នឹងតាំងនៅបានព្រោះចិត្តនិងអារម្មណ៍ប៉ះគ្នា កាលចិត្តនិងអារម្មណ៍មិនប៉ះគ្នាហើយ ឬនាមនិងរូបមិនផ្សំគ្នាទេ នឹងឈ្មោះថាសត្វជាបុគ្គលក៏ពុំបានឬថាមានជីវិតក៏ពុំបាន ។ ធម្មតាចិត្តតាំងពីបដិសន្ធិរហូតដល់ចុតិឈ្មោះថាភវង្គ គឺចិត្តជាអង្គនៃភព ឬជាគ្រឿងសំគាល់នៃជាតិភវង្គចិត្តនេះ កាលឃើញអារម្មណ៍ឯណានិមួយហើយ វិថីចិត្តរមែងកើតឡើងជានិច្ច ប្រព្រឹត្តទៅក្នុង ៣ ខណៈតូច គឺឧប្បាទៈ

ឋិតិ និងភង្គ បានចិត្តក្ខណៈ ១ ខណៈ ចិត្តក្ខណៈ ១៧ ខណៈ នេះជាអាយុនៃរូបធម៌ ទើបធ្លាក់ក្នុងភវង្គចិត្តតាមដើមវិញ ៗ ដូច្នេះនាមធម៌តែងកើតឡើងហើយរលត់បាត់ទៅគ្រប់ៗ ខណៈចិត្ត ឯរូបធម៌តែងកើតឡើងហើយរលត់បាត់ទៅគ្រប់ៗ ១៧ ខណៈចិត្ត គឺយើងតែងកើតស្លាប់ កើតស្លាប់គល់វេលា តែដោយសារនាមធម៌រលរហ័សជាងរូបធម៌ ហើយមានការរលនោះជានិច្ចជាប់តៗ គ្នាទៅដោយអំណាចសន្តតិ ទើបឃើញថារូបនេះនៅគង់វង្សដរាប ៗ កំណើតថ្មីតែងមានពិតប្រាកដ កម្មនាំឲ្យចាប់ជាតិជាថ្មី ព្រោះជាប់ជំពាក់នឹងកងកាយដែលនាំយកសេចក្តីសប្បាយក្រើតក្រើនក្រេបខ្លួនមកឲ្យ ឯកម្មដែលយើងបានធ្វើមកហើយគត់បាត់បង់សាបសូន្យទៅណាទេ នៅចាំតាមឲ្យផលជានិច្ច បីដូចស្រមោលដែលតែងអន្ទោលតាមប្រាណ ៗ

ព្រោះហេតុនោះ បើយើងចង់ឲ្យបានជួបប្រទះនូវអមតធម៌ នូវសេចក្តីសុខបរិបូណ៌ឥតខ្វះចន្លោះ យើងគោងតែខិតខំសំរិតសំរាំងនូវកម្មរបស់យើងឲ្យបានល្អជានិច្ច កុំបីរង់ចាំពេលវេលា, គប្បីលៃលកយកការប្រែប្រួលដោយឆាប់រហ័សនៃជីវិតមកពិចារណា ដើម្បីកសាងខ្លួន កសាងកំណើតរបស់យើងឲ្យសមនឹងសំរេចនូវសេចក្តីបំណងរបស់យើងគ្រប់ប្រការ កុំឲ្យក្រេបខ្លួនឃ្លាតចាកឆ្ងាយអំពីវត្ថុបំណងនេះ ៗ

សុភមិត្ត

អក្សរសាស្ត្រជាពន្លឺជាតិ ជាគោលបារិកជាតិ

អក្សរសាស្ត្ររលត់ ជាតិរលត់ ។

## ប្រវត្តិព្រះពុទ្ធវង្ស ម៊ី

(ដកស្រង់អំពីប្រវត្តិដែលព្រះពោធិវង្ស ហ-គាត បានរៀបរៀង ទុកខាងដើមសៀវភៅទសធម្មសូត្រ)

ព្រះពុទ្ធវង្ស ម៊ី មាននាមក្នុងភិក្ខុភាវៈថា ឥន្ទសារបញ្ញោ, ជាតិជាខ្មែរ, បិតាឈ្មោះទេព, មាតាឈ្មោះ អ៊ឹង ។ លោកកើតនៅថ្ងៃអាទិត្យ ១៥ កើតខែស្រាពណ៍ ឆ្នាំខាលអដ្ឋស័ក ព.ស. ២៤០៨ (គ.ស. ១៨៦៦) នៅភូមិកំពង់ទួលស្រុកមុខកំពូល ខេត្តកណ្ដាល ។

កាលកុមារម៊ីបានអាយុ ១៣ ឆ្នាំ, ក្នុងឆ្នាំខាលសំរឹទ្ធិស័ក ព.ស. ២៤២១ (គ.ស. ១៨៧៩), បិតាបាននាំយកទៅឲ្យនៅសិក្សាអក្សរខ្មែរក្នុងសំណាក់លោកគ្រូ ម៉ុក ជាមា នៅវត្តដងគោម ឃុំកំពង់ទួល ។ ដល់អាយុ ១៨ ឆ្នាំ កុមារម៊ី បានបួសកាន់ផ្នួសជាសាមណេរក្នុងសំណាក់លោកគ្រូសីរីគន្ធានុវង្ស ម៉ៅ វត្តសុន្ទរគហបតី (វែកព្រែកបណាក) ឃុំកំពង់ហ្លួងស្រុកពញាឮ ខេត្តកណ្ដាលនៅថ្ងៃសុក្រ ខែអាសាឍ ឆ្នាំមមែ បញ្ចស័ក ព.ស. ២៤២៦ (គ.ស. ១៨៨៤) ។ ក្នុងអាយុគំរប់ ២០ ឆ្នាំ, បានបំពេញឧបសម្បទជាភិក្ខុ នៅវត្តដដែលមានលោក

គ្រូសិរីគន្ធានុវង្ស ជាឧបជ្ឈាយ៍, លោកគ្រូ គប់ និងលោកគ្រូ ឈឹម ជាឧបសម្បទាចារ្យ ៗ លុះដល់អាយុ ២២ ឆ្នាំ, ភិក្ខុ ម៉ី បានមកនៅវត្តឧណ្ណាលោមភ្នំពេញ ហើយបានសូមនិស្ស័យក្នុងសំណាក់សម្តេចព្រះមហាសង្ឃរាជ ព្រះនាមទៀង ជានិស្សយាចារ្យ ៗ លោកបានសិក្សាព្រះបរិយត្តិធម៌ក្នុងសំណាក់ព្រះអាចារ្យជាច្រើនរូប មានលោកគ្រូព្រះពោធិវង្សកឹង (ជាតិសៀម) និងលោកឧកញ៉ាសុធម្មមេធាវ៉ត (ភដបណ្ឌិត) ជាដើម ដរាបដល់បានចេះដឹងយ៉ាងមុតមាំៗ

ដោយយល់ឃើញថា ភិក្ខុ ម៉ី មានបំណេះធ្លាតវាងវៃព្រមទាំងកិរិយាមារយាទនិងសេចក្តីប្រតិបត្តិរៀបរយសមគួរតាមពុទ្ធោវាទ ព្រះពោធិវង្ស កឹង ក៏បានចាត់ឲ្យធ្វើអាចារ្យបង្រៀនព្រះបរិយត្តិធម៌ដល់ភិក្ខុសាមណេរទាំងឡាយ រួចតមក បានតាំងឲ្យធ្វើជាសមុហ៍របស់លោកមានងារជាព្រះសមុហ៍ពោធិញាណ ៗ កាលព្រះសមុហ៍ពោធិញាណម៉ី មានអាយុ ៣៧ ឆ្នាំ, សម្តេចព្រះមហាសង្ឃរាជ ទៀង ទ្រង់ព្រះមេត្តាប្រោសអនុញ្ញាតតាំងជាព្រះបាឡាត់សង្ឃវង្ស ជាបាឡាត់សម្រាប់ក្រសួងទ្រង់ ៗ លុះដល់មកឆ្នាំរកាឯកស័ក ព. ស. ២៤៥១ (គ. ស. ១៩០៩) ក្នុងកំណត់អាយុ ៤៣ ឆ្នាំ, ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ទ្រង់ព្រះមេត្តាប្រោសតាំងព្រះបាឡាត់សង្ឃវង្សម៉ីជាព្រះពុទ្ធវង្ស ទីរាជាគណៈព្រមទាំងគោរម្យងារជាព្រះពុទ្ធវង្ស សមណពង្សវិសុទ្ធិបរិយាមហាបិដកត្រ័យ, បន្ទាប់មក

ក្នុងឆ្នាំដដែលនេះ ទ្រង់បានតាំងលោកឲ្យធ្វើជាចាងហ្វាងសាលាបាលី នៅទីនគរវត្ត សៀមរាប ព្រោះសម័យនោះរាជការបានបង្កើតសាលាបាលី ១ នៅទីនោះ ។ ដល់មកក្នុងឆ្នាំជូតបញ្ចស័ក ព.ស. ២៤៥៤ (គ.ស. ១៩១២) ព្រះករុណាស៊ីសុវត្ថិ ទ្រង់បានតាំងលោកឲ្យធ្វើជាអាំង-ស្ប៉ិចទ័រវិញ មាននាទីជាអ្នកត្រួតត្រាការសិក្សាបឋមវិជ្ជាអក្សរខ្មែរគ្រប់សាលាវត្តក្នុងកម្ពុជា ។ ព្រះពុទ្ធវង្សម៉ីបានទទួលធ្វើការក្នុងតំណែងនោះតមក ដោយសេចក្ដីប្រឹងប្រែងបង់ឲ្យអក្សរសាស្ត្រខ្មែរបានលូតលាស់ចំរើនឡើងតាមកាលសម័យ ។ របៀបអក្សរខ្មែរយើងក្នុងជំនាន់នោះ នៅជារបៀបចាស់ខ្វះនៅឡើយ ។ ក្នុងឆ្នាំ ១៩១២ នោះ រាជការបានរៀបចំកែប្រែអក្សរខ្មែរខ្វះៗ មានការបន្ថែមស្រៈ អឹ, អឺ, ឱង អឿ ជាដើម បានចាត់ព្រះពុទ្ធវង្សម៉ីដែលធ្វើជាអាំងស្ប៉ិចទ័រ ឲ្យនិមន្តទៅគ្រប់វត្តក្នុងខេត្តផ្សេងៗ ពន្យល់រៀបចំអំពីរបៀបកែប្រែអក្សរនេះ ទាល់តែមានរបៀបរៀបរយល្អតមក ។ តាំងលទ្ធិព្រះពុទ្ធសាសនា ក៏លោកយកព្រះទ័យឈ្លាលណាស់ទៅទៀត កាលនិមន្តទៅដល់វត្តនីមួយៗ លោកមិនមែនពន្យល់តែអំពីរបៀបអក្សរសាស្ត្រខ្មែរប៉ុណ្ណោះទេ, លោកឆ្លៀតហៅប្រជុំពួកបព្វជិតនឹងគ្រហស្ថមកបង្ហាត់ឲ្យសូត្រធម៌អាថ៌ផ្សេងៗ ឲ្យបានត្រឹមត្រូវតាមទីឃៈរស្សៈ ហើយរំលឹកដាស់តឿនឲ្យប្រឹងប្រែងរៀនសូត្រប្រតិបត្តិតាមធម៌វិន័យទៀតផង ។ ហេតុដូច្នេះសេចក្ដីចំរើននៃអក្សរសាស្ត្រខ្មែរនិង

ពុទ្ធសាសនា ឃើញថាបានរើបលេចមុខទៀត ដោយសារស្នាដៃរបស់ព្រះថេរអង្គនេះជាច្រើន ។

ព្រះពុទ្ធវង្ស ម៉ី ចេះភាសាបាលី អក្សរ-ភាសាខ្មែរបុរាណ ទាំងអក្សរភាសាសៀម ។ ឯកិច្ចការស្នាដៃដែលលោកបានធ្វើទុកនោះ គឺអក្ខរាវិធីអក្សរខ្មែរ, ប្រែភាណវារៈបាលីត្រង់សត្តបរិត្ត, ប្រែទសធម្មសូត្រព្រមទាំងអធិប្បាយ, ច្បាប់សម្រាប់បង្រៀនកុមារជាច្រើនបែប ជាពាក្យរាយខ្លះ ពាក្យកាព្យខ្លះ ។

ព្រះពុទ្ធវង្ស ម៉ី បានយកព្រះទ័យទុកដាក់ធ្វើការតាមនាទីរបស់លោកដរាបមកទល់នឹងជន្មាយុគំរប់ ៦៣ ឆ្នាំ, លោកក៏ទទួលអនិច្ចធម្មទៅដោយ-រោគាពាធមួយដែលបណ្ដាលមកអំពីរោគទល់, នៅថ្ងៃអាទិត្យ ២ កើតខែបុស្សឆ្នាំរោងសំរឹទ្ធិស័ក ព.ស. ២៤៧១ (២៧-១-២៩) ក្នុងវត្តសុន្ទរ-គហាបតិ (ព្រែកប្រណាក) ឃុំកំពង់ហ្លួងស្រុកពញាឮខេត្តកណ្ដាល ។

(យើងមានសេចក្ដីស្ដាយច្រើន ដោយស្រាវជ្រាវរកស្នាដៃជាពាក្យកាព្យរបស់លោកពុំទាន់ឃើញនៅឡើយ ។ កាលណារកឃើញបានមក នឹងចុះផ្សាយតទៅថ្ងៃក្រោយ) ។

## ក្បួនមេកាព្យ

មេកាព្យដែលចុះតៗទៅនេះ យើងបានស្រង់អំពីក្បួនរបស់លោក-អ្នកឧកញ៉ាសុត្តន្តប្រីជាឥន្ទ យកមកផ្សាយចែកចាយដល់អ្នកសិក្សាកាព្យទាំងឡាយទុកជាច្បាប់សំរាប់តែងកាព្យឲ្យបានល្អ ដោយបេះរបៀបកាព្យច្រើនបទ នឹងសំរាប់វិនិច្ឆ័យកាព្យនៃកវីឯទៀត ដោយសមហេតុសមផល តែយើងមានសេចក្តីស្តាយជាបំផុតដោយមិនអាចយករបៀបតែងធៀប មកចុះទាំងមូលបានព្រោះទស្សនាវដ្តីរបស់យើងមានទំព័រតិចពេក ។

## ១ — ពំនោល

កាព្យទី ១ នេះ ឈ្មោះពំនោល ក្នុង ១ គាថាមាន ៣២ ពាក្យ កំណត់ជា ៤ បាទ ។ បឋមបាទនឹងតតិយបាទមានពាក្យ ៦ ដូចគ្នា ទុតិយបាទនឹងចតុត្ថបាទមានពាក្យ ១០ ដូចគ្នា ។ អក្សរស្រៈទី ៦ នឹងទី ១០ ជាគូគ្នា ១ អក្សរស្រៈទី ១៦ ទី ២២ នឹងទី ២៦ ជាគូយាមុខគ្នា ១ មានលំនាំដូច្នេះ



### បែបតែងធៀប

ពំនោលពោលកាលគ្រុឌា ហៀរហោះវេហាស៍នេត្រគន់នាគានាគី
យល់នាគមួយស្មើគិរី លេងក្នុងជលធីអនោត្តហោមហ៍ ។

គ្រុឌកាន់ស្វាបការកំណត់ បិទសែនស្បូវ្រាមេ យានដឹតជិតជុំ
ហើយហក់ចុះឆក់ឆាប់រំ- ពេចដល់នាគធំក្រញាំករជុំផាន់ផាប់ៗ

## ២ - ភុជង្គលីលា

ក្នុង ១ គាថាមាន ២៨ ពាក្យ ចែកជា ៤ បាទ បាទទី ១ នឹងទី ៣ មាន ៦ ពាក្យដូចៗ គ្នា បាទទី ២ នឹងទី ៤ មាន ៨ ពាក្យដូចៗ គ្នា ៗ ឯទទួលយាមុខនោះគឺ ពាក្យទី ៦ នឹងទី ១០ ជាគូគ្នា ១ ពាក្យទី ១៤ ទី ២០ នឹងទី ២៤ ជាគូគ្នា ១ ៗ មានលំនាំដូច្នេះ




បែបតែងធៀប

បទទ្រង់ភុជង្គលីលា កាលក្រុងនាគារួចពីជើងគ្រុឌ
ភិតភ័យហឫទ័យស្ទើរផុត ពិរោធពិរុធនឹងគ្រុឌពេកក្រៃ ៗ
ខំមុជផ្ដែកខ្សែជលស័យ ដំរង់ត្រង់ឰបាតាលភព
ពិសក្រុធរឹងពើតមហិមា ពេលផ្សព្វកាយាកក្រាមហ្វាន ៗ

## ៣ - បន្ទោលកាក

ក្នុង ១ គាថាមាន ៤ បាទ បាទទី ១ នឹងទី ៣ មាន ៤ ពាក្យដូចៗ គ្នា បាទទី ២ នឹងទី ៤ មាន ៦ ពាក្យដូច ៗ គ្នា ត្រូវជា ២០ ពាក្យក្នុង ១

គាថា ៗ កំណត់ទទួលយាមុខនោះគឺ ពាក្យទី ៤ នឹងទី ៨ ជាគូគ្នា ១ ពាក្យទី ១០ ទី ១៤ នឹងទី ១៨ ជាគូគ្នា ១ មានលំនាំដូច្នេះ




បែបតែងធៀប

បទបទ្មោលគាក ថ្ងៃកាលគ្រុឌលាកនាគា
ហោះឡើងវេហាស៍ វិលទៅព្រឹក្សសិម្ពលី ៗ
ដល់ហើយចូលថ្នាត់ វិមានថ្នារត្នាយមណី
កើតឃ្លានចំណី បក្សីនិត្យនឿយអង្គប្រាណ ៗ

## ៤– នាគកៀវក្រវ៉ាត់

កាព្យនេះក្នុង ១ ឃ្លាមាន ៧ ពាក្យ ៤ ឃ្លាជាកាព្យ ១ រួមជា ២៨ ពាក្យ មានលំនាំដូចតទៅនេះ



បែប តែងធៀប

សូន្យសុងបាត់តាំងអង្គនូវសូរសព្ទ សព្ទសូរមិនបែងប្រាប់ដំណឹងប្អូន
ប្អូននឹងដឹងការសោះចប់ជួន ជួនចប់តែខ្លួនម្នាក់ឯកឯង ៗ
ឯងឯកវិវេកទៅតាមកម្ម កម្មតាមមកសាំស៊ូហួតហែង
ហែងហួតដូចម្ដេចស្រេចបុណ្យព្រេង ព្រេងបុណ្យផងឯងដែលសាងមកៗ

## ៥ – កង្កែបលោតកណ្ដាលស្រែះ (ពាក្យ ៧)



ក្នុង ១ ឃ្លា ពាក្យទី ១ ត្រូវគ្នានឹងពាក្យទី ៧ អក្សរទី ១ នឹង ៣ ត្រូវគ្នា អក្សរទី ២ នឹងអក្សរទី ៤ ត្រូវគ្នា ។

### បែបតែងធៀប

គិតមេគេមិនមេត្តាគិត  គ្រឹកបង់ត្រង់ចិត្តពិនិត្យគ្រឹក
ខ្សឹកអួលខ្សួលអនិយោគខ្សឹក  សល់ណែនសែននឹករលឹកសល់ ។
កម្ចាមកាមតាំងកំឡុំងកម្ច  ផលនៃភ័យនាំកម្ចឲ្យផល
ខ្វល់កាយខ្វាយការវល់ខ្វល់  គិតម្ដេចគេចផ្ដល់អម្ពល់គិត ។

## ៦ – អក្សរល្បួន (ពាក្យ ៧)

កាព្យនេះមានអក្សរដូចគ្នាទាំង ៧ ពាក្យក្នុង ១ ឃ្លាៗ ។



### បែបតែងធៀប

រឿងរៀមរ័ងរែងរិះរៀងកល់  ទោរទន់ទុក្ខទ័លទៀតទៀងទាត់
សុបសៅស៊ុបសួរសង្សារសត្វ  កែវកាត់កាមក្ដួចកែកេក្ដិកាយ ។

## ៧ – សុក្រិទំនវិណាស (ពាក្យ ៧)

ពាក្យទី ៧ ត្រូវប្ចួននឹងពាក្យទី ១៣ ពាក្យទី ១៤ នឹងពាក្យទី ២១ នឹងពាក្យទី ២៣ ឬ ២៥ ត្រូវប្ចួនគ្នា ។ លំនាំដូច្នេះ



បែបតែងធៀប

នៃកែវវរលក្ខណ៍ក៏ក្រនិមល កែវបង យ៉ាងផុំស្កប់ស្កល់ប្រាណ
ស្ងួនភ្ងាបើកទ្វារឲ្យបងបាន ឃើញមុខកល្យាណបងនឹងលា ។
កែវបងមិនគួរធ្វើដូច្នេះ បងទឹកអាល័យស្រណោះណា
សូមធ្វើជាប្ដីស្រីពុំងា ឃើញជារងាគ្រាម្ដងហ្នឹង ។

## ៨ – សោរទិសវិលាស (ពាក្យ ៣)

វិធីបួន ពាក្យ ៧ បួននឹងពាក្យទី ១៤ ពាក្យ ១៤ នឹងពាក្យទី ២១ ២៣ ឬ ២៥ មានលំនាំដូច្នេះ -



បែបតែងធៀប

គួរអើយគួរព្រេងៗ វាសនា បងមិនល្អួងលោមទេកល្យាណ៍
បញ្ឆោតក្បត់ករគួរស្នេហា ឲ្យខូចអាសាបានទុក្ខា ។
បងស្បថជូនអ្នកមិនគួរណា លន់តួតាមទោសឲ្យកនិដ្ឋា
ផ្ទង់ល្អងជាស្ដេចគ្រងសីមា ម្ដេចគ្មានពន់តានឹងរួមរក្ស ។

## ៩ – ត្រឡាបឡើងទ្រើង (ពាក្យ ៣)

វិធីចួន ពាក្យទី ១ ត្រូវចួននឹងពាក្យទី ៧ ទី ២ នឹងទី ៣ ទី ៤ នឹង ទី ៥ ពាក្យទី ៤ តាមតែដូច្នេះគ្រប់ឃ្លាទាំង ៤ ដូចគំនូរនេះ



ចួបចួនទួនអកផាក់នៃបចួប    នៅឃួបចួបឃិតនិត្យឃើញនៅ
ពៅស្ទិទពិតស្មាលពាលស្នេហ៍ពៅ    គិតបង់ណាក្នុងយៅនៅតែគិត ៗ
ចិត្តណែនសែនធ្ងួលគួលកង់ចិត្ត    មិត្តខូចដូចខោចកោចដូចមិត្ត
ក្តៅចិត្តត្បូតពាកណាកចិត្តក្តៅ    ផ្តល់ទុក្ខមួយផ្តលធ្ងូលទ្រង់ផ្តល់ៗ

(នោមាឧត)

---

## ពាក្យផាប់ទង

| | | |
|---|---|---|
| បួនអើយបង់គិត | គិតកែវពេកពិត | ពិតពុំភ្នាំងក្បួច |
| ក្បួចកោផនា | នាគាលណាខេច | ខេចទៅគិតខ្ទួច |
| ខ្ទួចខ្ទាំក្ដួលក្តៅ ៗ | ស្រមៃមាសមិត្ត | មិត្តមូលដូបជិត |
| ជិតជាមួយនៅ | នៅនៃបម្ដចឡើយ | ភ្ញាក់ហើយបាត់ពៅ |
| ពៅអើយបង់ក្ដៅ | ក្ដៅពន់ពេកក្រែ ៗ | កែវអើយចិត្តបង់ |
| បង់ប៉ង់សួនគ្រង់ | គ្រង់អ្នកមាសថ្ងៃ | ថ្ងៃថ្មើមផឹក |
| ស្នេហាសព្វថ្ងៃ | ថ្ងៃណាក្បៀណក្បួយ | ក្បួយឲ្យព្រមគ្នា ៗ |

(សន្ធរ មុ៉ក)

# ការសាងអាយតន

ធម្មតាមនុស្សយើងដែលកើតឡើងហើយ តែងមានរោគចូលមកបៀតបៀនដល់អាយតនៈទាំងឡាយ បើប្រសិនជាយើងមិនខំប្រឹងព្យាបាលអាយតនៈទាំងឡាយនោះ តាមគម្រោងវេជ្ជសាស្ត្រទេ អាការរោគនោះនឹងធ្វើឲ្យខូចអាយតនៈណាមួយ, កាលបើខូចហើយ គេសន្មតថាជាមនុស្សខ្វះសំណាងអំពីអតីត ហេតុនេះត្រូវតែខំប្រឹងប្រែងការពារអាយតនៈទាំងឡាយនោះ ឲ្យរឹងប៉ឹងឡើង ។

កិច្ចការពារអាយតនៈទាំងឡាយ ឲ្យមានសុខភាពបរិបូណ៌នេះ មានច្រើនបែបច្រើនយ៉ាងណាស់ ប៉ុន្តែខ្ញុំសូមពោលដោយសង្ខេបមាន ២ យ៉ាង :

១ – ត្រូវសំអាតទីសេនាសនៈ, គ្រឿងសំលៀកបំពាក់, គ្រឿងបរិភោគ ប្រើឥរិយាបថទាំង ៤ ឲ្យស្មើនឹងការហាត់ប្រាណឲ្យមានកំឡាំងមួនមាំ ។

២–រោគដែលកើតឡើងហើយ មិនត្រូវបណ្ដែតបណ្ដោយ ឲ្យជ្រុលហួសប្រមាណទេ ត្រូវតែប្រញាប់រកគ្រូពេទ្យនឹងឱសថផ្សេងៗមកព្យាបាលឲ្យទាន់ពេលវេលា កុំឲ្យធ្លាក់ទៅជាជម្ងឺហួសវិស័យថ្នាំ និងវិស័យគ្រូពេទ្យព្យាបាលបាន ។

៣៩១

កាលបើយើងបានការពារអាយតនៈទាំងឡាយ ឲ្យតាំងនៅក្នុងសុខភាពដ៏បរិបូណ៌ហើយ យើងត្រូវដឹងច្បាស់ថា "សំណាងអតីត" របស់យើងមានសភាពដ៏មួនមាំ អាចនឹងទទួលនូវសេចក្ដីចំរើនបាន ។ ប៉ុន្ដែការដែលនឹងទទួលនូវសេចក្ដីចំរើននោះ មិនមែនអាចនឹងទទួលបាន ដោយខ្វះការបង្ហាត់បង្រៀនអាយតនៈទាំងឡាយនោះឲ្យចេះចាំស្គាល់នូវវិជ្ជាដែលមានផលប្រយោជន៍ណាមួយឡើយគឺថា ត្រូវតែរៀនមើល, រៀនស្ដាប់, រៀនស្រង់ក្លិន, រៀននិយាយ, រៀនធ្វើ, រៀនគិតតទៅទៀត ។

## សាងភ្នែក

ភ្នែកអាចមើលឃើញបានហើយ តែបើមិនកសាងការឃើញនោះ ឲ្យប្រព្រឹត្តទៅតាមផ្លូវដែលត្រូវឲ្យកើតផលប្រយោជន៍ទេ ភ្នែកទុកជាមិនបានការ ។

ស – ការកសាងភ្នែកដូចម្ដេច ទើបមើលឃើញហើយបានផលប្រយោជន៍ផង ?

ឆ – មុនដំបូង ត្រូវកសាងភ្នែកដោយការរៀនមើលអក្សរ លេខនព្វន្ត ឲ្យបានចេះដឹងសព្វគ្រប់ រួចហើយត្រូវស្រាវជ្រាវយកក្បួនច្បាប់គម្រាវិទ្យាសាស្ដ្រផ្សេង ៗ មកពិនិត្យសង្កេតមើលឲ្យចាំ ហើយការកផលប្រយោជន៍ ដែលអាចញ៉ាំងអាជីវកម្មឲ្យប្រព្រឹត្តទៅបាន ដោយក្បួនច្បាប់នោះៗ ។

មួយទៀត ត្រូវសង្កេតមើល ឲ្យជាក់ច្បាស់នូវរបៀបបែបផែន, ដំណើរទំនងនៃកិច្ចការទាំងឡាយផង នៃអាការរបស់បុរសស្ត្រីទាំងឡាយផងថា: របៀបនេះ សមឬមិនសម? បែបផែននេះ ថ្លៃថ្នូរឬទេ? ដំណើរទំនងនេះ ជាការស្រួល ឬជាការទំនាស់, ជាអាការៈនៃបុគ្គលសុចរិត ឬទុច្ចរិត; ត្រូវកែសម្រួល ឬធ្វើតាម? ត្រូវដំកល់ទុក ឬបដិសេធចោល ដោយសេចក្ដីវិនិច្ឆ័យនៃបញ្ញាចក្ខុរបស់ខ្លួន ។

ស – ភ្នែកក្ដីហើយ ហេតុអ្វី បានជាត្រូវកសាងដូច្នេះទៀត?

ឆ – បើមិនសាងភ្នែកឲ្យចេះទទួលនូវអារម្មណ៍ ដែលមានប្រយោជន៍ មកប្រគល់ឲ្យចិត្តទេ ចិត្តដែលជាអ្នកឃុំគ្រងទុកនូវអារម្មណ៍ ក៏មិនអាចនឹងចាត់ចែងការងារទាំងឡាយ ដោយបញ្ញាចេតសិកជាអ្នកណែនាំបានឡើយ ។ ព្រោះថារូបារម្មណ៍ទាំងឡាយ ដែលស្រូបចូលមកតាមភ្នែក មិនមែនសុទ្ធតែនាំឲ្យចំរើនទាំងអស់ទេ មានអារម្មណ៍ខ្លះនាំឲ្យវិនាស អារម្មណ៍ខ្លះនាំឲ្យចំរើន បើភ្នែកជាអ្នកស្ទាត់ជំនាញក្នុងការជ្រើសរើសនូវអារម្មណ៍ ដែលគួរយកមកប្រើការ ឬមិនគួរយកមកប្រើការ ដោយវិធីដែលខ្លួនបានកសាងហើយក្នុងបច្ចុប្បន្ននោះទើបហៅថាភ្នែកមានសំណាង ។

## សាងត្រចៀក

ត្រចៀកជាអ្នកទទួលរ៉ាប់រងខាងសំឡេង ។ សំឡេងទាំងឡាយ ដែលហូរចូលមកតាមត្រចៀក មិនមែនសុទ្ធតែដឹកនាំរូបបុរស - ស្ត្រី

តាំងឡាយ ឲ្យទៅកាន់សេចក្តីចំរើនទាំងអស់ទេ មានសំឡេងខ្លះដឹកនាំឲ្យវិនាសដែរ ។ ហេតុដូច្នេះត្រូវតែយើងចំរកសាន់ត្រចៀកនោះតទៅទៀត ដើម្បីកែអប់រំឲ្យទៅជាត្រចៀកមានសំណាង ។

ស – ការសាន់ត្រចៀក ដូចម្តេចខ្លះ?

ឆ – មុនដំបូងត្រូវរៀនស្តាប់សង្កេតសំឡេង ៖ សំដីទាំងឡាយដែលខ្លួនបានជួបប្រទះ ហើយកត់សំគាល់ទុក ដើម្បីពិចារណាដោយឧបាយនៃប្រាជ្ញា ថាសំឡេងឬសំដីនេះ បើខ្លួនចាំប្រឹងយកចិត្តទុកដាក់ប្រតិបត្តិតាម តើនឹងឲ្យផលដល់ខ្លួនដូចម្តេចខ្លះ បើមិនប្រតិបត្តិតាមទេនឹងខូចប្រយោជន៍របស់ខ្លួនដូចម្តេចខ្លះ បើនឹងយកសំឡេងឬសំដីនេះ មកជាទីពឹង តើខ្លួននឹងតាំងនៅក្នុងសេចក្តីចំរើនបានឬទេ? ។

សំឡេងឬសំដីនេះ អាចដឹកនាំទឹកចិត្តរបស់ខ្លួន ឲ្យធ្លាក់ចុះទៅកាន់អំពើដ៏ថោកទាប ឬឲ្យស្ទុះទៅកាន់អំពើដ៏ខ្ពង់ខ្ពស់? ។ សំឡេងឬសំដីនេះ គេពោលដោយទោសចិត្ត, ដោយមេត្តាចិត្ត, ដោយរាគ-ចិត្ត, ដោយលោភចិត្ត, ឬដោយមោហចិត្ត? ។ សំឡេងឬសំដីនេះជាបណ្ឌិតភាសិតឬជាពាលភាសិត? សំឡេងឬសំដីរបៀបនេះ តើគេមានបំណងឲ្យអ្នកស្តាប់ ប្រែចិត្តគំនិតរបៀបណា? ឲ្យស្ទុះទៅកាន់អំពើណា? ឲ្យបានប្រយោជន៍អ្វីដល់គេ? ឲ្យបានប្រយោជន៍អ្វីដល់ខ្លួន? ឲ្យបានប្រយោជន៍អ្វីដល់បណ្តាជនទូទៅ? ។

ក្នុងចំនួននៃពាក្យទាំងអស់នេះ សេចក្ដីត្រង់ណាខ្លះ ដែលឥតប្រយោជន៍? ត្រង់ណាខ្លះ ដែលមានប្រយោជន៍? គួរបដិសេធពោលត្រង់ណា? គួរស្រង់យកត្រង់ណា? ។

បើពោលដោយខ្លីថា សំឡេងឬសំដីដូចម្ដេចក៏ដោយ បើអ្នកបេះស្ដាប់ សុទ្ធតែអាចយកមកធ្វើជាគតិពិចារណាដេញដោលរកហេតុផលបានទាំងអស់ ។ លោកសំដែងថា ត្រូវរៀនស្ដាប់ឲ្យច្រើនទើបកើតប្រាជ្ញាហៅថា សុតាមយបញ្ញា, បើមិនខំស្វាហាប់រៀនស្ដាប់ទេ ត្រចៀកមិនអាចនឹងស្វែងរកប្រយោជន៍អ្វីមួយបានឡើយ ហើយនឹងបានឈ្មោះថា ត្រចៀកឥតសំណាង" ។

## សាងច្រមុះ

ច្រមុះ មានភ្នាក់ងារខាងទទួលស្រង់យកក្លិន ឯក្លិនទាំងឡាយក្នុងលោកមិនមែនដូចគ្នាទាំងអស់ទេ មានក្លិនខ្លះជាឥដ្ឋារម្មណ៍ ក្លិនខ្លះជាអនិដ្ឋារម្មណ៍ ប៉ុន្តែការហាត់រៀនឲ្យមានវិជ្ជាស្រង់យកក្លិននេះ មិនមែនឥតប្រយោជន៍ទេ របស់ទាំងឡាយក្នុងលោក សុទ្ធតែមានក្លិនជាសំគាល់ឲ្យដឹងថាខូចទៅហើយជិតនឹងខូចឬមិនទាន់ខូចនៅឡើយទេ ។

(មាគត)

១២៨ – ភ្លើងជាទឹកអម្រឹតក្នុងរដូវសិសិរ (រងា), ការជួបប្រទះជនជាទីស្រឡាញ់ពេញចិត្តជាទឹកអម្រឹត, ការប្រោសប្រាណនៃព្រះរាជាជាទឹកអម្រឹត គោជនលាយដោយទឹកដោះជាទឹកអម្រឹត(១) ។

គ្រានោះ ចចកទមនក:ចូលទៅកាន់សំណាក់គោសញ្ជីវក: ហើយនិយាយប្រាប់ដោយសេចក្ដីរាក់ទាក់ថា "នែសម្លាញ់អើយ! អញបានចូលទៅសូមប្រទានអភ័យទោសចំពោះលោកម្ចាស់ ៗ ក៏ព្រមប្រទានអភ័យទោសឲ្យសមតាមសេចក្ដីបំណងឯងហើយ ឯងចូរជឿទុកចិត្តហើយមកតាមអញចុះ តែបើឯងបានប្រោសប្រាណពីព្រះរាជាហើយ ត្រូវឯងធ្វើខ្លួនសន្យានឹងអញទៀត គឺឯងមិនត្រូវព្រហើន នឹងមិនត្រូវធ្វើការអ្វីស្រេចតែទំនើងចិត្តឯងទេ, ឯខ្លួនឯងវិញ បើអញបានឡើងឋានៈជារដ្ឋមន្ត្រីបរិហារការៈរាជការផែនដីទាំងអស់ អញធ្វើអ្វីៗ ក៏ធ្វើដោយសេចក្ដីព្រមព្រៀងពីឯងវិញដែរ បើយើងបានធ្វើដូច្នេះហើយ យើងមុខជាបានរីករាយសប្បាយក្នុងមុខការផែនដីជាមួយគ្នាមិនខាន, ព្រោះថា:

១២៩ – ទ្រព្យសម្បត្តិទាំងអស់ តែងនៅក្នុងអំណាចនៃនរជនតាមច្បាប់អ្នកបរបាញ់សម្លាប់ ក្នុងលោកនេះ អ្នកមួយធ្វើសេវកស្គាល់ព្រះរាជា អ្នកមួយទៀតសម្លាប់ ដូចគេសម្លាប់ម្រឹគ ។

---

១ ទីខ្វះថា ការសេពគប់លោកសប្បុរស ជាទឹកអម្រឹត ។

១៣០— នរជនណា មិនគោរពជនឧត្តម ជនគួរ នឹងជនមជ្ឈិម ដោយសេចក្ដីព្រហើន នរជននោះ សូម្បីគេត្រូវគោរពព្រោះខ្លួនជាទីប្រោសប្រាណនៃព្រះរាជា ក៏ត្រូវអន្តរាយខ្លួន ដូចពាណិជឈ្មោះទន្តិល:" ។

គោសញ្ជីវក:សួរឡើងថា: "ចុះរឿងនោះគេដូចម្ដេច?" ។ ចចកទមនក:និយាយរៀបរាប់រឿងនោះប្រាប់ថា:–

កថាទី ៤

## រឿងពាណិជទន្តលៈ ស្ដេច នឹងអ្នកបោសគោរម្ភៈ

នៅលើផកតលនេះ មាននគរមួយឈ្មោះវធិមាន: ។ នៅក្នុងក្រុងនោះ មានពាណិជម្នាក់ឈ្មោះទន្តិល: ជាអ្នកមានទ្រព្យសម្បត្តិច្រើន ហើយជានាយត្រួតត្រាក្រុងទាំងមូលនោះផង ។ ពាណិជនោះ ទទួលបន្ទុកធ្វើការជាចៅហ្វាយក្រុងផង ធ្វើជាការថ្វាយព្រះរាជាផង មហាជនព្រមទាំងព្រះរាជា ដែលនៅក្នុងក្រុងទាំងប៉ុន្មាន មានសេចក្ដីពេញចិត្តចំពោះគាត់ដ៏ក្រៃលែង ។ បើនិយាយដោយខ្លី គ្មានអ្នកណាមួយបានឃើញឬបានឮថា មានអ្នកឯទៀតប្រសប់ប៉ិនប្រាកដដូចពាណិជនោះសោះឡើយ, ព្រោះថា:

១៣១ – ក្នុងលោកនេះ អ្នកដែលយកចិត្តទុកដាក់ធ្វើប្រយោជន៍ថ្វាយព្រះនរបតីតែម្យ៉ាង ត្រូវប្រជាជនគេស្អប់ខ្ពើម, អ្នកដែលយកចិត្ត

ទុកដាក់ធ្វើប្រយោជន៍ឲ្យប្រជាជនក្នុងជនបទតែម្យ៉ាង ត្រូវព្រះនរេន្ទ្រ-ធិបតីបោះបង់ចោល កាលបើមានចំនាស់ធំពីរប្រការកើតប្រាកដដូច្នេះហើយ បុគ្គលដែលយកចិត្តទុកដាក់ធ្វើការថ្វាយព្រះនរបតីផង ឲ្យអ្នកជនបទផងជាបុគ្គលក្រកោបាន ។

ថ្ងៃមួយចំណោរតមក, ពាណិជទន្តិល: រៀបចំធ្វើពិហាមង្គលការកូនផ្ទះខ្លួន ។ ក្នុងពិហាមង្គលការនោះ គាត់បានអញ្ជើញអ្នកក្រុងព្រមទាំងរាជបុរសទាំងឡាយមករៀបលៀងភោជន ហើយចែកជូនវត្ថុទាំង-ឡាយមានសំពត់អាវជាដើមដោយសេចក្តីរាប់អានដ៏ក្រៃលែង ។ ពេលក្រោយពិហាមង្គលការនោះ ពាណិជទន្តិល: អញ្ជើញព្រះរាជាព្រមទាំងនាម៉ឺនក្នុងផ្ទៃព្រះរាជវាំងទៅកាន់គេហដ្ឋានខ្លួន ហើយគោរពបូជាដោយបណ្ឌិតភោជនីយាហារ ។ កាលនោះ រាជសេវកម្នាក់ឈ្មោះគោរម្ភ: ជាអ្នកបោសសំអាតព្រះរាជនិវេសន៍ ក៏ត្រូវពាណិជអញ្ជើញដែរ ។ គោរម្ភ:នេះចូលទៅអង្គុយថ្នាក់ខ្ពស់ជាងរាជបុរោហិតនៃព្រះរាជា ត្រង់កន្លែងមិនសមគួរដល់ខ្លួន, ពាណិជឃើញដូច្នោះ ក៏យកដំបងដៃច្បាមកច្រានបណ្តេញចេញទៅក្រៅផ្ទះ ។ តាំងពីថ្ងៃនោះមក គោរម្ភ:មួម៉ៅក្តៅក្រហាយចិត្តនឹងការគេមើលងាយនោះខ្លាំងណាស់ រហូតដល់យប់ក៏ដេកមិនលក់សោះ នឹកផ្អកៗក្នុងពោះថា "ធ្វើម្តេចអេះ នឹងរក•បាយបំផ្លិចបំផ្លាញពាណិជនេះឲ្យសាបសូន្យ កុំឲ្យព្រះរាជាទ្រង់ប្រោសប្រាណ

តទៅទៀតបានហ្ន៎? ហើយកុំកើតទុក្ខបុកម្នេញក្តៅក្រហាយនាំឲ្យស្គម ខ្លួនឥតអំពើ មិនថ្វីទេ អាត្មាអញគង់នឹងអាចរកឧបាយបំផ្លាញឲ្យទាល់តែបានសម្រេចមិនខាន, ព្រោះថា:–

១៣២– ក្នុងលោកនេះ នរជនណាក្តៅក្រហាយនឹងគេ មិនអាចបំផ្លិចបំផ្លាញគេ ហើយមកដេកក្រវៃក្រោធខ្លួនឯង នរជននោះ ម្តេចក៏មិនចេះខ្មាសគេហ្ន៎? មែនពិត នរជននោះ ប្រៀបដូចសណ្តែកដែលគេលីងលោតអញ្ចើល ផ្ទុះប្រែះៗ នៅក្នុងខ្ទះ តែមិនអាចបំបែកខ្ទះបាន” ។

ក្នុងពេលបច្ចូសសម័យថ្ងៃមួយ ព្រះរាជាទ្រង់កំពុងរៀបចំនិទ្រា គោរម្ភ:ចូលទៅបោសសំអាតជិតបុងព្រះទែនសយនាពោលវាចាថា: “ឃើអើ! ទន្តិល:នេះចិត្តធំអីម៉្លេះហ្ន៎ ហ៊ានចាប់ឧបព្រះរាជអគ្គមហេសី” ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យគោរម្ភ:នោះហើយ ទ្រង់ក្រោកយ៉ាងរហ័សត្រាស់សួរភ្លាមទៅកាន់គោរម្ភ:ថា: “នែគោរម្ភ: ឯងនិយាយថាទន្តិល:ចាប់ឧបនាងទេវី ពាក្យនេះជាពាក្យពិតមែនឬអ្វី?” ។ គោរម្ភ:ឆ្លើយក្រាបទូលថា: “បពិត្រព្រះទេវរាជ! ទូលព្រះបង្គំជាខ្ញុំជាប់ចិត្តនឹងល្បែងនៅទើសក្លី មិនបានទទួលព្រះរាជទានដំណេកក្នុងរាត្រីនេះសោះ អស់កំឡាំងពេកលន់លក់ទាំងកំពុងបោស, រឿងនេះ, ទូលព្រះបង្គំជាខ្ញុំមិនដឹងជាទូលព្រះបង្គំជាខ្ញុំនិយាយដូចម្តេចទេ” ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ហើយមានព្រះទ័យប្រែចណ្ណ ទើបទ្រង់ព្រះចិន្តាថា: “គោរម្ភ:

នេះកំផ្លាប់ចូលមកកាន់សំណាក់យើងដោយសេរី ទន្តិល:នេះក៏ដូចគ្នាដែរ ចំនែងជាគោរម្ភនេះកំបានឃើញទន្តិល:ចាប់នុបនាងទេវីមែន បានជាក រអិលមាត់ក្លាត់ពោលពាំងមិនដឹងខ្លួន ព្រោះថា :–

១៣៣ – របស់អ្វីមួយដែលគេចង់បាន, ឬគេមើលឃើញ ពុំនោះ គេធ្វើក្នុងវេលាថ្ងៃ ដល់ពេលដេកលក់ គេនឹងនិយាយឬធ្វើការនោះៗ តាមទម្លាប់ដែលគេចង់បាន គេមើលឃើញ ព្រមទាំងគេធ្វើ ។

១៣៤ – អំពើល្អ ឬក៏ អំពើអាក្រក់ណា ដែលឋិតនៅក្នុងចិត្ត នៃនរជនទាំងឡាយ បើទុកជាគេខំលាក់បំបិទបំបាំងយ៉ាងណា បុគ្គល គប្បីដឹងបាននូវអាថ៌កំបាំងនោះ ដោយពាក្យមមើក្នុងពេលដេកលក់ ឬ ក្នុងពេលស្រវឹង ។

មួយទៀត, រឿងនេះ បុគ្គលមិនគួរនឹងសង្ស័យចំពោះចិត្តស្ត្រីភាព ទាំងឡាយទេ ។

១៣៥ – ស្ត្រីនិយាយជាមួយនឹងប្រុសម្នាក់ តែភ្នែកក្រឡេកមើល ទៅប្រុសម្នាក់ទៀតដោយក្ដីក្លើតក្លើន ឯចិត្តគិតទៅប្រុសម្នាក់ទៀតដែល ឋិតនៅក្នុងចិត្តខ្លួន, តើប្រុសណាមួយ ដែលឈ្មោះថាជាទីស្រឡាញ់នៃ ស្ត្រីទាំងឡាយ? ។

១៣៦ – ស្ត្រីទាំងឡាយខ្សឹបខ្សៀវច្រើនជាមួយប្រុសម្នាក់ ដោយ ទឹកមុខស្រស់ដ៏មានពណ៌ក្រហមទុំ ហើយញញឹមពព្រាយ ក្រឡេក

មើលទៅប្រុសម្នាក់ទៀតដោយភ្នែកបើកធំ ក្រឡេបក្រឡាប់ក្ដីផ្ដេកដូចផ្កាឈូករីក, ចិត្តគិតស្នងទៅប្រុសម្នាក់ទៀតនៅឆ្ងាយ ដែលមានទ្រព្យសម្បត្តិច្រើនសុទ្ធសឹងវិសេស ហើយពុកពាថ្ងៃថ្នូរ, ដូច្នេះ បើតាមបរមត្ថ, ប្រុសណាអេះ ដែលស្ត្រីមានរូបល្អប្រដាប់ដោយកេមចិញ្ចើមមូលក្រឡង់ ចាប់ចិត្តស្រឡាញ់ពិតប្រាកដ? ។

១៣៧ -- ភ្លើង មិនឆ្អែតដោយឧសទាំងឡាយ មហាសមុទ្រមិនឆ្អែតដោយទឹកទន្លេទាំងឡាយ សេចក្ដីស្លាប់មិនឆ្អែតដោយមនុស្សទាំង-ឡាយ ស្ត្រីមានរូបល្អ មិនឆ្អែតដោយប្រុសទាំងឡាយ ។

១៣៨ -- មិនមានទីស្ងាត់ មិនមានពេលមួយខណៈ មិនមានប្រុសចង់បាន ឱតាបសនារទ:! សេចក្ដីបរិសុទ្ធនៃស្ត្រីទាំងឡាយ កើតដោយហេតុមានប៉ុណ្ណោះឯង ។

១៣៩ – អ្នកណាល្ងង់ខ្លៅ សំគាល់ដោយគំនិតច្រឡំថា “នាងនេះស្រឡាញ់អាត្មាអញ” ដូច្នេះ អ្នកនោះនឹងលុះក្នុងអំណាចនៃនាងនោះអស់កាលជានិច្ច ទុកដូចសត្វសេកដែលគេដាក់ក្នុងទ្រុងសំរាប់មើលលេង ។

១៤០ – អ្នកណា និយាយ ឬធ្វើកិច្ចការ គោះតិចឬច្រើន ជាមួយស្ត្រីទាំងឡាយនោះ អ្នកនោះ នឹងត្រូវគេមើលងាយគ្រប់កាលទាំងពួនក្នុងលោកនេះដោយទម្លាប់ដែលខ្លួនធ្វើនោះៗ ។

(មាតរ)

រោងពុម្ពព្រះរាជទ្រព្យ

IMPRIMERIE ROYALE